ជាអ្នកទទួលផលអ្នកមានសិទ្ធិ ៖

- ត្រូវបានទទួលដោយការគោរព និងការពិចារណាសម្រាប់សេចក្តីថ្លៃថ្នូរ និងភាពឯកជនរបស់អ្នក
- ទទួលព័ត៌មានពីជម្រើសព្យាបាល និងជម្រើសផ្សេងទៀត ដែលបង្ហាញក្នុងរបៀបត្រឹមត្រូវនឹងស្ថានភាព និងសមត្ថភាពយល់ដឹងរបស់អ្នក
- ចូលរួមក្នុងការសម្រេចទាក់ទងនឹងការថែទាំសុខភាពរបស់អ្នក ដែលរាប់បញ្ចូលទាំងសិទ្ធិបដិសេធការព្យាបាល
- មានសេរីភាពពីការបង្ខិតបង្ខំគ្រប់ទម្រង់ ឬការដាក់ឲ្យនៅដាច់ពីគេដែលប្រើជាវិធីនៃការបង្ខិតបង្ខំ ការដាក់វិន័យ ភាពងាយស្រួល ឬការសងសឹក
- ស្នើសុំ និងទទួលច្បាប់ចម្លងនៃកំណត់ត្រាសុខភាពរបស់អ្នក និងស្នើសុំឲ្យពួកវាត្រូវបានសម្រួល ឬកែប្រែ
- ទទួលព័ត៌មានស្របតាមមាត្រា 42 CFR ផ្នែក 438.10 ដែលពណ៌នាពីតម្រូវការព័ត៌មាន
- ត្រូវបានផ្គត់ផ្គង់សេវាកម្មថែទាំសុខភាពស្របតាមមាត្រា 43 CFR ផ្នែក 438.206 ដល់ 438.210 ដែលគ្របដណ្តប់តម្រូវការសម្រាប់ការប្រើសេវាកម្ម ការធានានៃសមត្ថភាពគ្រប់គ្រាន់និងសេវាកម្ម ការសម្របសម្រួលនិងការបន្តការថែទាំ និងធានារ៉ាប់រងនិងការផ្តល់សិទ្ធិសេវាកម្ម ។

មណ្ឌលឡូស អេនជីលេស — នាយកដ្ឋានសុខភាពផ្លូវចិត្ត ការិយាល័យសិទ្ធិរបស់អ្នកជម្ងឺ

(213) 738- 4949 – សារទុក្ខ និងបណ្តឹងឧទ្ធរណ៍មិននៅមន្ទីរពេទ្យ

(213) 738- 4888 – សារទុក្ខ និងបណ្តឹងឧទ្ធរណ៍មន្ទីរពេទ្យ

dmh.lacounty.gov

មណ្ឌលឡូស អេនជីលេស ក្រុមប្រឹក្សានៃអ្នកគ្រប់គ្រង

Hilda L. Solis
Mark Ridley-Thomas
Sheila Kuehl
Janice Hahn
Kathryn Barger

មណ្ឌលឡូស អេនជីលេស ក្រសួងសុខភាពផ្លូវចិត្ត ការិយាល័យសិទ្ធិរបស់អ្នកជម្ងឺ

សារទុក្ខនិងបណ្តឹងឧទ្ធរណ៍មិននៅមន្ទីរពេទ្យ
(213) 738-4949

សារទុក្ខ និងបណ្តឹងឧទ្ធរណ៍មន្ទីរពេទ្យ
(213) 738-4888
(800) 700-9996

MH638E Rev. 1/2015

មណ្ឌលឡូស អេនជីលេស

ក្រសួងសុខភាពផ្លូវចិត្ត

នីតិវិធីសារទុក្ខ និងបណ្តឹងឧទ្ធរណ៍

ការណែនាំរបស់អ្នកជម្ងឺ

នីតិវិធីសារទុក្ខ និងបណ្តឹងឧទ្ធរណ៍

នាយកដ្ឋានសុខភាពផ្លូវចិត្តគឺជាគម្រោងសុខភាពផ្លូវចិត្តក្នុងតំបន់ (MHP) សម្រាប់មណ្ឌលឡូស អេនជឺលេស ។ បើអ្នកកំពុងទទួលសេវាកម្មឯកទេសសុខភាពផ្លូវចិត្តក្រោម MHP អ្នកមានសិទ្ធិទទួលបានសេវាកម្មដែលត្រឹមត្រូវនឹងពិការភាព វប្បធម៌ ភាសា អាច និងអាយុរបស់អ្នក ។ អ្នកនឹងទទួលសេវាកម្មដែលរួមគ្នាកំណត់ដោយអ្នក និងអ្នកផ្តល់សេវាកម្មសុខភាពផ្លូវចិត្តរបស់អ្នក ។ ពួកយើងលើកទឹកចិត្តឲ្យអ្នកចូលរួមយ៉ាងសកម្មក្នុងការថែទាំរបស់អ្នក និងបង្ហាញការព្រួយបារម្ភរបស់អ្នកដោយប្រើដំណើការសម្រេច ។

របៀបដំណើការសម្រេចបញ្ហាធ្វើការ ៖

អ្នកអាចដោះស្រាយការព្រួយបារម្ភរបស់អ្នក ដោយនិយាយដោយផ្ទាល់ជាមួយអ្នកផ្តល់សេវាកម្ម ឬអ្នកតំណាងកម្មវិធីសុខភាពផ្លូវចិត្តរបស់អ្នក។

អ្នកអាចស្នើសុំជំនួយពីការិយាល័យសិទ្ធិរបស់អ្នកជម្ងឺ ។ អ្នកការពារនឹងធ្វើការជាមួយអ្នកដើម្បីដោះស្រាយបញ្ហាដែលអ្នកមានជាមួយអ្នកផ្តល់សេវាកម្ម ឬសេវាកម្មរបស់អ្នក ។

អ្នកការពារសិទ្ធិរបស់អ្នកជម្ងឺអាចរកបាននៅ ៖

- **(213) 738-4949** សម្រាប់សារទុក្ខ និងបណ្តឹងឧទ្ធរណ៍មិននៅមន្ទីរពេទ្យ
- **(213) 738-4888** សម្រាប់សារទុក្ខ និងបណ្តឹងឧទ្ធរណ៍មន្ទីរពេទ្យ

អ្នកអាចដាក់បណ្តឹងដោយផ្ទាល់មាត់ ឬជាលាយលក្ខអក្សរគ្រប់ពេល ។ អ្នកអាចទទួលបានប៉ែបបទសម្រាប់បណ្តឹងរបស់អ្នកពីអ្នកផ្តល់សេវាកម្មសុខភាពផ្លូវចិត្តរបស់អ្នក ឬពីការិយាល័យសិទ្ធិរបស់អ្នកជម្ងឺ ។

អ្នកអាចផ្តល់សិទ្ធិឲ្យអ្នកផ្សេងធ្វើសកម្មភាពជំនួសអ្នក ។

អ្នកនឹងមិនមែនជាកម្មវត្ថុការធើសធើង ឬទោសទណ្ឌផ្សេងទៀតសម្រាប់ការដាក់បណ្តឹង ។

សម្រាប់អ្នកទទួលផល MEDI-CAL

អ្នកមានសិទ្ធិប្តឹងឧទ្ធរណ៍ជាមួយការិយាល័យសិទ្ធិរបស់អ្នកជម្ងឺ ឬស្នើសុំ**សវនាការយុត្តិធម៌រដ្ឋ**ពេលដែល MHP បដិសេធ កាត់បន្ថយ ផ្អាស់ប្តូរ ឬលុបចោលការទូទាត់សម្រាប់សេវាកម្មសុខភាពផ្លូវចិត្តរបស់អ្នក ថាតើអ្នកទទួល ឬមិនបានទទួល**សេចក្តីប្រកាសនៃសកម្មភាព (NOA)** ពីអ្នកផ្តល់សេវាកម្មសុខភាពផ្លូវចិត្តរបស់អ្នក ។ **NOA** គឺជាឯកសារដែលបានផ្តល់ឲ្យអ្នកទទួលផល ដោយអ្នកផ្តល់សេវាកម្មរបស់ពួកគេ ដែលជូនដំណឹងពីការផ្លាស់ប្តូរសេវាកម្ម ។

សវនាការយុត្តិធម៌រដ្ឋ គឺជាការពិនិត្យឡើងវិញដោយឯករាជ្យដែលធ្វើដោយក្រសួងសេវាកម្មសង្គមរដ្ឋ ។ សវនាការធ្វើឲ្យប្រាកដថាអ្នកទទួលសេវាកម្មសុខភាពផ្លូវចិត្តដែលអ្នកមានសិទ្ធិទទួលក្រោម MHP ។

អ្នកអាចស្នើសុំសវនាការយុត្តិធម៌រដ្ឋ លុះត្រាតែអ្នកជាអ្នកទទួល Medi-Cal និងពេលអ្នកបានបំពេញដំណើរការបណ្តឹងឧទ្ធរណ៍របស់ MHP ។

បើអ្នកចង់បានសវនាការយុត្តិធម៌រដ្ឋ សំណើរបស់អ្នកត្រូវតែធ្វើក្នុងរយៈពេល 30 ថ្ងៃពីកាលបរិច្ឆេទដែលអ្នកទទួល***សេចក្តីប្រកាសនៃសកម្មភាព*** ។ អ្នកអាចស្នើសុំបន្ត 14 ថ្ងៃបន្ថែម ។

ការពន្យារជំនួយបង់ថ្លៃ

បើអ្នកទទួល***សេចក្តីប្រកាសនៃសកម្មភាព*** អ្នកមានសិទ្ធិទទួល **ការពន្យារជំនួយបង់ថ្លៃ** បើអ្នកទាក់ទងការិយាល័យសិទ្ធិរបស់អ្នកជម្ងឺក្នុងរយៈពេល 10 ថ្ងៃ ។ *ការពន្យារជំនួយបង់ថ្លៃ* នឹងអនុញ្ញាតឲ្យអ្នកបន្តទទួលសេវាកម្មសុខភាពផ្លូវចិត្តពី MHP ខណៈដែលអ្នកនៅក្នុងដំណើរការនៃការមានសវនាការយុត្តិធម៌រដ្ឋ ។

បើអ្នកទទួល***សេចក្តីប្រកាសនៃសកម្មភាព*** អ្នកអាចស្នើសុំ "ពន្ធឿន" ឬដំណោះស្រាយរហ័សនៃ**បណ្តឹង ឧទ្ធរណ៍**របស់អ្នកនៅក្រោមស្ថានភាពធ្ងន់ធ្ងរ ។

ការិយាល័យសិទ្ធិរបស់អ្នកជម្ងឺនឹងជួយអ្នកក្នុងការស្នើសុំសវនាការយុត្តិធម៌រដ្ឋ ។ ដើម្បីស្នើសុំសវនាការយុត្តិធម៌រដ្ឋដោយខ្លួនឯង ទូរស័ព្ទទៅ (800) 952-5253 ឬសរសេរទៅ ៖

ផ្នែកការវិនិច្ឆ័យរដ្ឋបាលក្រសួងសេវាកម្មសង្គមរដ្ឋ ផ្លូវ 744 P Mail Station 19-37 Sacramento, CA 95814

សេវាកម្មឯកទេសសុខភាពផ្លូវចិត្តមាន ៖

សេវាកម្មអ្នកជម្ងឺផ្លូវចិត្តសម្រាកក្នុងមន្ទីរពេទ្យ
សេវាកម្មវិកលចរិត
សេវាកម្មចិត្តវិជ្ជា
ការគ្រប់គ្រងករណីគោលដៅ
ការពិនិត្យជាមុន និងក្នុងរយៈពេលកំណត់
ធាតុវិនិច្ឆ័យ និងការព្យាបាល (EPSDT)
សេវាកម្មស្តារនីតិសម្បទា
សេវាកម្មកន្លែងថែទាំវិកលចរិត

របៀបទទួលបានសេវាកម្ម

ទូរស័ព្ទទៅមជ្ឈមណ្ឌលទូរគមនាគមន៍ ACCESS តាមលេខ (800) 854-7771 ។ សម្រាប់សេវាកម្ម TDD/TTY ទូរស័ព្ទទៅ (562) 651-2549 ។

សម្រាប់បញ្ជីអ្នកផ្តល់សេវាកម្ម ទូរស័ព្ទទៅ ACCESS ឬការិយាល័យសិទ្ធិរបស់អ្នកជម្ងឺតាមលេខ (213) 738- 4949 ឬចូលគេហទំព័រ DMH ៖

dmh.lacounty.gov

ព័ត៌មានសំខាន់ ៖

- ដើម្បីស្នើសុំផ្លាស់ប្តូរអ្នកផ្តល់សេវាកម្ម អ្នកអាចនិយាយជាមួយអ្នកផ្តល់សេវាកម្មរបស់អ្នក និងការិយាល័យសិទ្ធិរបស់អ្នកជម្ងឺ ។
- ការសម្ងាត់របស់អ្នកនឹងត្រូវបានការពារគ្រប់ពេលស្របជាមួយច្បាប់រដ្ឋ និងសហព័ន្ធ ។
- សៀវភៅព័ត៌មាននេះ និងឯកសារទាក់ទងមានជាទម្រង់ផ្សេងទៀត ។
- អ្នកដែលស្នើសុំទាក់ទងមានជាទម្រង់ផ្សេងទៀត អាចទាក់ទងការិយាល័យសិទ្ធិរបស់អ្នកជម្ងឺតាមលេខ (800) 700-9996 ឬ (213) 738-4888.
- អ្នកមានបញ្ហានិយាយ ឬស្តាប់ត្រូវបានទាក់ទងតាមរយៈសេវាកម្មបន្ទូរដ្ឋកាលីហ្វូនីញ៉ា (800) 735-2929 ។
- មណ្ឌលឡូស អេនជឺឡេស ក្រសួងសុខភាពផ្លូវចិត្តមិនធើសធើសលើមូលដ្ឋាននៃពិការភាពក្នុងការចុះឈ្មោះ និងទទួលបានសេវាកម្ម កម្មវិធី ឬសកម្មភាព ។

អ្នកមានសិទ្ធិទទួលបានសេវាកម្មជំនួយភាសាដោយឥតគិតថ្លៃ